# ប្រកាសដំណើរការគេហទំព័រទិន្នន័យ Cambodia Urban Database

ខណៈពេលដែលតំបន់ទីក្រុង ឬទីប្រជុំជន ក្នុងប្រទេសកម្ពុជា មានការរីកចម្រើន និងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ឯកសារស្រាវជ្រាវ និងទិន្នន័យដែលមានគុណភាពខ្ពស់ ស្តីអំពីនគរូបនីយកម្ម មានសារៈសំខាន់ដើម្បីគាំទ្រដល់ចំណេះដឹង និងគោលនយោបាយ។ **មជ្ឈមណ្ឌលខេមរសិក្សា** នាពេលថ្មីៗនេះ បានដាក់ដំណើរការ គេហទំព័រទិន្នន័យ Cambodia Urban Database ដែលជាឃ្លាំងឯកសារសិក្សា អំពីទីក្រុងនៅ ក្នុង ប្រទេសកម្ពុជា។ គេហទំព័រទិន្នន័យដែលដាក់ឱ្យសាធារណៈជនប្រើប្រាស់នេះ ប្រមូលផ្តុំដោយ របាយការណ៍ស្រាវជ្រាវ អត្ថបទទិនានុប្បវត្តិ កម្រងទិន្នន័យបែបបរិមាណ ផែនការមេ ផែនទី រូបភាព និងប្រភេទ ឯកសារជាច្រើនទៀត។

គោលបំណងចម្បងៗនៃគេហទំព័រទិន្នន័យ Cambodia Urban Database រួមមាន៖

- គាំទ្រដល់ការសិក្សា និងស្រាវជ្រាវ របស់សិស្ស និស្សិត និងអ្នកស្រាវជ្រាវ ដែលចាប់អារម្មណ៍ លើប្រធានបទ ទីក្រុងនៅកម្ពុជា
- ជួយបំភ្លឺគម្លាតនៃចំណេះដឹងអំពីប្រធានបទទីក្រុងនៅកម្ពុជា
- រួមចំណែកក្នុងការកសាងសហគមន៍ចំណេះដឹងសម្រាប់ការស្រាវជ្រាវអំពីប្រធានបទដែលទាក់ទងនឹងទីក្រុងនៅកម្ពុជា

## ពង្រីកលទ្ធភាពទទួលបានចំណេះដឹងលើការសិក្សាអំពីទីក្រុងនៅកម្ពុជា

**បណ្ឌិត យ៉េន យ៉ាត** អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលខេមរសិក្សា ដែលបានចូលរួមក្នុងកិច្ចការបង្កើត គេហទំព័រទិន្នន័យមួយនេះ បានលើកឡើងថា៖ «ទិន្នន័យគឺជាអ្វីៗគ្រប់យ៉ាង សម្រាប់ការស្រាវជ្រាវ។ គួរឱ្យស្តាយ អ្នកស្រាវជ្រាវជាច្រើន នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដូចជាកម្ពុជា នៅតែជួបការលំបាក ក្នុងការស្វែងរកទិន្នន័យ និងប្រភពឯកសារ ហើយឯកសារដែលអាចរកបានជាឯកសារមានគុណភាពទាប។ អ្នកស្រាវជ្រាវ វ័យក្មេង និងសិស្ស និស្សិតជាច្រើន មិនដឹងថាត្រូវទៅស្វែងរកចំណេះដឹងនៅកន្លែងណា។ គេហទំព័រទិន្នន័យនេះ គឺជាបណ្ណុំឯកសារយ៉ាងសំខាន់ សម្រាប់ជួយដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវ ក៏ដូចជាដើម្បីពង្រឹង សមត្ថភាពក្នុងការសិក្សាស្រាវជ្រាវអំពីទីក្រុងនៅកម្ពុជា។»

ជាមួយឯកសារជាង៥០០ ត្រូវបានដាក់បញ្ចូល និងបន្តកើនឡើងបន្ថែមទៀតនៅលើគេហទំព័រថ្មីនេះ សាធារណៈជនអាចស្វែងរកឯកសារទៅតាមប្រភេទ ប្រធានបទ និងតំណភ្ជាប់ទៅកាន់ទិន្នន័យបន្ថែម ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់ពួកគេ។

អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលខេមរសិក្សាមួយរូបទៀតគឺ **បណ្ឌិត ធួន ទ្រី** បាននិយាយថា៖ «ខ្ញុំអាចប្រើគេហទំព័រទិន្នន័យ Cambodia Urban Database ដើម្បីរកមើលបានភ្លាមៗ ថាតើចំណេះដឹងដែលពាក់ព័ន្ធនឹងការស្រាវជ្រាវរបស់ខ្ញុំណាខ្លះត្រូវបានបោះពុម្ពផ្សាយរួចហើយ (ឬមិនទាន់)។ សម្រាប់សិស្ស របស់ខ្ញុំ ឥឡូវនេះ ពួក

គាត់មានកន្លែងចាប់ផ្តើមមួយសម្រាប់ស្វែងរកប្រភពឯកសារ ដែលពីមុនមក ភាគច្រើន ពួកគាត់មិនដឹងថា តើឯកសារណាខ្លះអាចរកបាន ហើយត្រូវទៅរកនៅកន្លែងណានោះទេ។»

**មជ្ឈមណ្ឌលខេមរសិក្សា** នឹងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រទិន្នន័យនេះ ដោយដាក់បញ្ចូលនូវធនធានឯកសារដែលទើបចេញថ្មីៗ ហើយអ្នកសិក្សាស្រាវជ្រាវទាំងអស់ ត្រូវបាន ស្វាគមន៍ដើម្បីចូលរួមចំណែកក្នុងកិច្ចការនេះ។ មជ្ឈមណ្ឌលខេមរសិក្សា ក៏មានគម្រោងបង្កើតឯកសារណែនាំ ដែលរួមមានគន្លឹះស្រាវជ្រាវ និងធនធានឯកសារបន្ថែមជាច្រើនទៀត ដើម្បីជួយពង្រឹងសមត្ថភាពសិស្ស និស្សិត និងអ្នកស្រាវជ្រាវវ័យក្មេងផងដែរ។

**មជ្ឈមណ្ឌលខេមរសិក្សា** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការឧបត្ថម្ភថវិកា របស់ **រដ្ឋាភិបាលអូស្ត្រាលី** តាមរយៈ **កម្មវិធីពន្លកចំណេះ របស់ អង្គការមូលនិធិអាស៊ី** ដែលធ្វើឱ្យគម្រោងនេះអាចដំណើរការ ទៅបាន។ **មជ្ឈមណ្ឌលខេមរសិក្សា** សូមគោរពអញ្ជើញលោកអ្នកសាកល្បងប្រើប្រាស់គេហទំព័រទិន្នន័យ Cambodia Urban Database និងចូលរួមជាមួយយើងខ្ញុំក្នុងព្រឹត្តិការណ៍សម្ពោធគេហទំព័រនេះ (ជាភាសាខ្មែរ) **នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩៖០០ - ១០៖០០ ព្រឹក** ដើម្បីស្វែងយល់បន្ថែមអំពីធនធានថ្មីដ៏គួរឱ្យរំភើបនេះ៕